## ជំពូកទី៩ : សន្និដ្ឋាន

**១៤៤.** តាមរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង **ហ្វ្រីន ខនសាល់ថិនស៊ី ហ្វឹម** សូមធ្វើការសន្និដ្ឋានដូចខាងក្រោម:

**១៤៥.** ការធ្វើផែនការលំអិតអំពីគំរោងស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែមាស នៅតំបន់ភ្នំដែករបស់ក្រុមហ៊ុន DELCOM (KAMPUCHEA) PTE. LTD. រៀបចំឡើងដោយធ្វើយ៉ាងណាអោយមានហេតុប៉ះពាល់ទាប ដូច្នេះគំរោងនេះអាចទទួលយកបានតាមលក្ខណៈបរិស្ថាន សង្គម និងមានភាពស្ថិតស្ថេរផ្នែកសេដ្ឋកិច្ច។

**១៤៦.** គំរោងនេះមិនបង្កអោយមានហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរទេ ហើយហេតុប៉ះពាល់ដែលពិនិត្យឃើញមាននៅក្នុងរយៈពេលនៃការវាយតំលៃនោះ អាចនឹងធ្វើកាត់បន្ថយបានតាមរយៈការអនុវត្តន៍នូវវិធានការណ៍កាត់បន្ថយ ដូចមានបង្ហាញនៅក្នុងតារាង ៧-១ និង ៧-៣។

**១៤៧.** នៅពេលដែលគំរោងទាំងមូលនេះដំណើរការបានពេញលេញ នោះនឹងនាំមកនូវផលប្រយោជន៍ជាច្រើនពាក់ព័ន្ធ និងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ទាំងសំរាប់សហគមន៍មូលដ្ឋាន និងជាតិ។

Draft

## ជំពូកទី១០ : អនុសាសន៍

**១៤៨.** ក្រុមហ៊ុនត្រូវឆ្លងផែនការផលិតកម្ម ក្នុងនោះមានទាំងប្រតិបត្តិការប្រព័ន្ធប្រព្រឹត្តកម្មសំណល់រឹង និងរាវ អោយទៅក្រសួងឧស្សាហកម្មពិនិត្យ ដើម្បីបញ្ជាក់អំពីសមត្ថភាពរបស់ប្រព័ន្ធនៅក្នុងដំណើរប្រព្រឹត្តកម្មសំណល់រឹង និងរាវ ដែលកើតមានពីដំណើរការអាជីវកម្មរ៉ែមាស ទើបអាចធានាបានថា សកម្មភាពពីដំណើរការអាជីវកម្មរ៉ែមាសនៅក្នុងតំបន់នេះ ពិតជាមិនធ្វើអោយប៉ះពាល់ទៅលើលក្ខណ:ក្សេត្រគីមីជីវ:របស់ដី និងការបំពុលទឹកស្រទាប់លើ និងស្រទាប់ក្រោមនៅក្នុងតំបន់។

**១៤៩.** ដើម្បីធានាបានថា ម្ចាស់គំរោងដើរតួនាទីសំខាន់នៅក្នុងការគ្រប់គ្រងបរិស្ថាន ទៅតាមវិធានការណ៍នៃការគ្រប់គ្រង ដូចបានលើកឡើងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន (EMP) និងឬក៏អនុវត្តន៍តាមទាំងស្រុងតាមវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ ដូចមានបញ្ជាក់នៅក្នុងតារាង ៧-១ និង ៧-៣ ក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចាំបាច់ត្រូវពិនិត្យការប្រតិបត្តិដោយយកចិត្តទុកដាក់តាមរយ:ការពិនិត្យតាមដានវាយតំលៃជាស្របចាំលើការអនុវត្តន៍ប្រព័ន្ធ ក៏ដូចជាការងារផ្សេងៗទៀត ដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថានផងដែរ។

| | |
|---|---|
| ភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១១ | ភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១១ |
| **នាយក** | **នាយកក្រុមហ៊ុន** |
| Green Consultancy Firm / KINGDOM OF CAMBODIA | DELCOM (KAMPUCHEA) PTE. LTD. |
| **បណ្ឌិត. លី_សុពណ៌_មុនី** | |

Draft